# ជំងឺអុតស្វា៖ អ្វីដែលអ្នកត្រូវស្វែងយល់

ជំងឺអុតស្វាគឺជាប្រភេទជំងឺឆ្លងមួយដែលបង្កឡើងដោយមេរោគអុតស្វា។ បុគ្គលណាម្នាក់ដែលមានទំនាក់ទំនងជិតស្និទ្ធដោយផ្ទាល់ជាមួយនឹងអ្នកដែលមានជំងឺអុតស្វា គឺប្រឈមនឹងហានិភ័យ។

## តើជំងឺអុតស្វារីករាលដាលយ៉ាងដូចម្តេច?

ជំងឺអុតស្វាត្រូវបានស្គាល់ថាជាជំងឺដែលអាចរីករាលដាលតាមរយៈទំនាក់ទំនងជិតស្និទ្ធ ព្រមទាំងការប៉ះពាល់ដែលជិតស្និទ្ធ និង/ឬទំនាក់ទំនងក្នុងរយៈពេលយូរផងដែរ ដែលរួមមាន៖

- ការប៉ះពាល់ស្បែកនឹងស្បែកដោយផ្ទាល់ជាមួយនឹងកន្ទួលរមាស់ ក្រមរ ឬសារធាតុរាវផ្សេងៗពីរាងកាយរបស់បុគ្គលដែលមានជំងឺអុតស្វា
- ការប៉ះពាល់ជាមួយនឹងរបស់របរ ឬសាច់ក្រណាត់នានា ដែលបានប្រើប្រាស់រួចដោយអ្នកដែលមានជំងឺអុតស្វា
- ការប៉ះពាល់ជាមួយនឹងសារធាតុរាវផ្សេងៗដែលចេញតាមផ្លូវដង្ហើមពីបុគ្គលដែលមានជំងឺអុតស្វា

ចំណុចនេះអាចកើតឡើងពី៖

- ការរួមភេទ ឬការប៉ះពាល់ជិតស្និទ្ធផ្សេងទៀតរួមទាំង ការថើប ការម៉ាស្សា ការឱបដោយថ្នាក់ថ្នម (cuddling) ផងដែរ
- ការប្រើប្រាស់សាច់ក្រណាត់នានា និងរបស់របរផ្សេងៗរួមគ្នា (ដូចជា សម្លៀកបំពាក់ កម្រាលពូកឬស្រោមខ្នើយ កន្សែងជូតខ្លួន ប្រដាប់ប្រដាលេងពេលរួមភេទ [sex toys]) ដែលមិនទាន់បានលាងសម្អាត
- ការមានទំនាក់ទំនងទល់មុខដោយផ្ទាល់ក្នុងរយៈពេលយូរ ដូចជាការនិយាយទល់មុខគ្នាយ៉ាងជិតក្នុងរយៈពេលយូរ (ប្រហែលចាប់ពី 3 ម៉ោងឡើងទៅ)
- ការរស់នៅក្នុងផ្ទះ ឬការគេងនៅលើគ្រែតែមួយ ឬក៏ការមើលថែទាំអ្នកដែលមានជំងឺអុតស្វា

បុគ្គលម្នាក់ដែលមានជំងឺអុតស្វា អាចចម្លងទៅកាន់អ្នកផ្សេងទៀតបាន គិតចាប់តាំងពីពេលដែលចាប់ផ្តើមកើតមានរោគសញ្ញា រហូតដល់កន្ទួលរមាស់បានជាសះស្បើយ ហើយក្រមរដំបៅបានរបកជ្រុះអស់ និងមានស្រទាប់ស្បែកថ្មីដុះឡើងវិញ។ ជាធម្មតា អាចត្រូវការរយៈពេលចន្លោះពី 2 ទៅ 4 សប្តាហ៍។

បុគ្គលដែលមានផ្ទៃពោះ ហើយដែលមានផ្ទុកជំងឺអុតស្វា អាចចម្លងមេរោគនេះបន្តទៅទារកនៅក្នុងផ្ទៃរបស់ពួកគេបាន តាមរយៈសុក។

**ជំងឺអុតស្វាមិនរីករាលដាល** តាមរយៈការសន្ទនាជាធម្មតា ឬក៏តាមរយៈការដើរក្បែរអ្នកដែលមានជំងឺអុតស្វានោះទេ។

## តើរោគសញ្ញានានានៃជំងឺអុតស្វាមានអ្វីខ្លះ?

**រោគសញ្ញាសំខាន់**

**កន្ទួលរមាស់**



កន្ទួលរមាស់នេះ អាច៖

- មើលទៅដូចជាឡើង ដុំពក មុន (លើស្បែក) ពងបែក ដំបៅ ឬឡើងក្រមរ
- ចេញនៅគ្រប់ទីកន្លែងនៅលើរាងកាយ រួមទាំងនៅលើប្រដាប់ភេទ ទ្វារធំ មាត់ ដៃ និងមុខផងដែរ
- ចេញនៅក្នុងកន្លែងតែមួយ ឬអាចរាលដាលពាសពេញរាងកាយ
- មានការរមាស់ ឬឈឺចាប់ (ជាពិសេសប្រសិនបើកើតមាននៅខាងក្នុងមាត់ ឬទ្វារធំ)

**រោគសញ្ញាផ្សេងទៀត**

**រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺគ្រុនផ្តាសាយធំ (flu)**



គ្រុនក្តៅ/គ្រុនរងា



ហើមកូនកណ្តុរ



អស់កម្លាំង ឈឺសាច់ដុំ និងឈឺក្បាល

- រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺគ្រុនផ្តាសាយធំទាំងឡាយអាចលេចឡើងក្នុងចន្លោះពេល 1 ទៅ 4 ថ្ងៃមុនពេលកន្ទួលរមាស់ចាប់ផ្តើមកើតមាន ឬក្រោយពេលកន្ទួលរមាស់ចាប់ផ្តើមកើតមានហើយ
- មិនមែនមនុស្សគ្រប់គ្នានឹងកើតមានរោគសញ្ញាទាំងនេះទេ

**ជាធម្មតា រោគសញ្ញានានាចាប់ផ្តើមកើតមានឡើងក្នុងចន្លោះពេល 5 ទៅ 21 ថ្ងៃបន្ទាប់ពីបានប៉ះពាល់ទៅនឹងមេរោគរួច**

### សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នក

ប្រសិនបើអ្នកមានកន្ទួលរមាស់ ឬដំបៅថ្មី ដែលខុសប្រក្រតី នៅលើផ្នែកណាមួយនៃរាងកាយរបស់អ្នក។ ការធ្វើបែបនេះមានសារៈសំខាន់ជាពិសេសប្រសិនបើអ្នកបានប៉ះពាល់ទៅនឹងនរណាម្នាក់ដែលមានជំងឺ ឬសង្ស័យថាមានជំងឺអុតស្វា។

### ប្រសិនបើអ្នកមិនមានគ្រូពេទ្យប្រចាំខ្លួនទេ៖

- សូមទូរស័ព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់សុខភាពសាធារណៈ (Public Health Call Center) តាម រយៈលេខ 1-833-540-0473 (មានផ្តល់សេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ) ឬក៏
- សូមទៅកាន់ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណៈ មួយដែលនៅជិតអ្នក។

**ស្កេនកូដ QR នេះ ដើម្បីស្វែងរកទីតាំងមួយ**

**For more information on Monkeypox, visit:**

ph.lacounty.gov/Monkeypox 8/26/2022 (Cambodian)

County of Los Angeles Public Health